ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី

## សកម្មភាព និងលទ្ធផល
## ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## ប្រចាំឆមាសទី១ ឆ្នាំ២០២៥

### របស់
### មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
### រាជធានីភ្នំពេញ

# របាយការណ៍
# សកម្មភាព និងលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆមាសទី១ ឆ្នាំ២០២៥
# របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ

## ១. **ស្ថានភាពមន្ត្រី** (ឧបសម្ព័ន្ធ ១)

មន្ត្រីរាជការកំពុងបម្រើការងារក្នុងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ មានចំនួនសរុប ១៥៦នាក់(ស្រី២៩នាក់) ក្នុងនោះមន្ត្រីក្របខ័ណ្ឌ"ក" ចំនួន៨៣នាក់(ស្ត្រី៩នាក់) ក្របខ័ណ្ឌ"ខ" ចំនួន៤៤នាក់(ស្ត្រី ១៤នាក់) ក្របខ័ណ្ឌ"គ" ចំនួន២៩នាក់(ស្ត្រី៦នាក់) និងមន្ត្រីជាប់កិច្ចសន្យាសរុបចំនួន០៨នាក់(ស្រី០២នាក់)។ នៅក្នុងឆមាសទី១ នេះដែរ មានមន្ត្រីបានចូលនិវត្តន៍ ចំនួន ២នាក់(ស្ត្រី១នាក់) មន្ត្រីបានផ្ទេរក្របខ័ណ្ឌទៅបម្រើការងារនៅអង្គភាពផ្សេង ចំនួន១នាក់ និងមន្ត្រីបានផ្លាស់ចូលមកពីអង្គភាពផ្សេង ចំនួន១នាក់ ។

## ២. សកម្មភាព និងលទ្ធផលការងារ

### ក. ការងារបង្កបង្កើនផល (ឧបសម្ព័ន្ធ ២)

**ក.១.ស្រូវរដូវប្រាំង ឆ្នាំ២០២៤-២០២៥** (ចាប់ផ្តើមពីខែវិច្ឆិកា ឆ្នាំ២០២៤ និងបញ្ចប់ត្រឹមខែមេសា ឆ្នាំ២០២៥)

- ផែនការ ៖ ២៨០ហ.ត (ស្មើគ្នា ធៀបផែនការឆ្នាំ២០២៣)
- ផ្ទៃដីភ្ជួររាស់សរុប ៖ ៣៤០ហ.ត « ភ្ជួររាស់ដោយគ្រឿងយន្ត »
- ផ្ទៃដីដាំដុះសរុប ៖ ៣៤០ហ.ត =១២១,៤៣%នៃផែនការ(ស្រូវពង្រោះ)
- ការប្រមូលផល ៖
  - ផ្ទៃដីប្រមូលផល : ៣៤០ហ.ត (បញ្ចប់ការប្រមូលផល)
  - បរិមាណផល : ១ ២១៧តោន
  - ទិន្នផល : ៣,៥៨តោន/ហ.ត។

**ក.២.ដំណាំរដូវប្រាំង ឆ្នាំ២០២៤-២០២៥** (ចាប់ផ្តើមពីខែវិច្ឆិកា ឆ្នាំ២០២៤ និងបញ្ចប់ត្រឹមខែមេសា ឆ្នាំ២០២៥)

- ដំណាំសាកវប្បកម្ម ៖ អនុវត្តបានសរុប: ១១០ហ.ត = ៩១,៦៦% នៃផែនការ ១២០ហ.ត
  - ផ្ទៃដីប្រមូលផល : ១១០ហ.ត (បញ្ចប់ការប្រមូលផល)
  - បរិមាណផល : ៩០៨តោន
  - ទិន្នផល : ៨,២៥តោន/ហ.ត។
- ដំណាំឧស្សាហកម្ម ៖ អនុវត្តបានសរុប: ៣០ហ.ត = ១០០% នៃផែនការ ៣០ហ.ត
  - ផ្ទៃដីប្រមូលផល : ៣០ហ.ត (បញ្ចប់ការប្រមូលផល)
  - បរិមាណផល : ៣៣០,៥០តោន
  - ទិន្នផល : ១១តោន/ហ.ត។

**ក.៣.ស្រូវរដូវវស្សា ឆ្នាំ២០២៥** (ចាប់ផ្តើមពីខែឧសភា ឆ្នាំ២០២៥

- ផែនការ ៖ ៤ ២០០ហ.ត (កើន១៣៤ហត ធៀបផែនការឆ្នាំ២០២៤)
- ផ្ទៃដីភ្ជួររាស់សរុប ៖ ៩៩១ហ.ត « ភ្ជួររាស់ដោយគ្រឿងយន្ត »
- ផ្ទៃដីសាប សរុប ៖ ២១ហ.ត
- ផ្ទៃដីដាំដុះសរុប ៖ ៩៩១ហ.ត =២៣,៥៩%នៃផែនការ
  - សន្ទូង ១១១ហ.ត
  - ពង្រោះ ៨៨០ហ.ត

**ក.៤.ដំណាំរដូវវស្សា ឆ្នាំ២០២៥** (ចាប់ផ្តើមពីខែឧសភា ឆ្នាំ២០២៥)

- ដំណាំសាកវប្បកម្ម ៖ អនុវត្តបានសរុប: ៧២ហ.ត = ៦០% នៃផែនការ ១២០ហ.ត
- ដំណាំឧស្សាហកម្ម ៖ អនុវត្តបានសរុប: ៣៥ហ.ត = ៨១,៣៩% នៃផែនការ ៤៣ហ.ត ។

### ក.៥. ផលប៉ះពាល់ដោយការរាំងស្ងួត និងការអន្តរាគមន៍សង្គ្រោះ

- នៅក្នុងខែមករា មានការរាំងស្ងួតបានបង្កផលប៉ះពាល់ដល់ដំណាំស្រូវរដូវប្រាំងសរុបចំនួន២១,៥០ហ.ត នៅសង្កាត់បឹងធំ ខណ្ឌកំបូល(ភូមិក្រោក ៨ហ.ត ភូមិដូនកុក ៣.៥ហ.ត និងភូមិខ្មៅ ១០ហ.ត) មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ បានសហការជាមួយមន្ទីរធនធានទឹករាជធានីភ្នំពេញ និងអាជ្ញាធរមូលដ្ឋានជួយអន្តរាគមន៍បូមទឹកជួយសង្គ្រោះទាន់ពេលវេលា។

### ក.៦.ការងារផ្សព្វផ្សាយ ណែនាំបច្ចេកទេស

- ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម ការិយាល័យផ្សព្វផ្សាយកសិកម្ម និងការិយាល័យគ្រឿងយន្តកសិកម្ម សហការជាមួយអាជ្ញាធរភូមិ-សង្កាត់នៅមូលដ្ឋាន ចុះផ្សព្វផ្សាយ ណែនាំបច្ចេកទេសពាក់ព័ន្ធនឹងការងារបង្កបង្កើនផលស្រូវ ដំណាំរដូវប្រាំង និងរដូវវស្សាជូនប្រជាកសិករ ។
- ការិយាល័យផ្សព្វផ្សាយកសិកម្មបានចុះណែនាំ និងចែករំលែកបទពិសោធន៍នៃការដាំដំណាំបន្លែរដូវវស្សានៅភូមិចំបក់មាស សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងបានចុះណែនាំ និងចែករំលែកបទពិសោធន៍ការដាំដុះដំណាំស្រូវដល់កសិករនៅសង្កាត់ទៀន ខណ្ឌដង្កោ រាជធានីភ្នំពេញ។
- ការិយាល័យនីតិកម្មកសិកម្ម សហការជាមួយមន្ត្រីរដ្ឋបាលខណ្ឌ និងអាជ្ញាធរមូលដ្ឋាន ចុះធ្វើបច្ចុប្បន្នភាព និងត្រួតពិនិត្យទីតាំងអាជីវកម្មថ្នាំកសិកម្ម និងជីកសិកម្មនៅក្នុងខណ្ឌកំបូល ខណ្ឌពោធិ៍សែនជ័យ ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌដូនពេញ រាជធានីភ្នំពេញ ។
- ការិយាល័យគ្រឿងយន្តកសិកម្ម ចុះប្រមូលទិន្នន័យអាកាសយានគ្មានមនុស្សបើក(ដ្រូន) នៅតាមទីតាំងលក់គ្រឿងយន្ត និងឧបករណ៍កសិកម្ម និងណែនាំម្ចាស់អាជីវកម្មទៅធ្វើស្វ័យប្រកាសជាមួយអាជ្ញាធរមូលដ្ឋាន ។
- ការិយាល័យកសិឧស្សាហកម្ម ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម និងការិយាល័យផ្សព្វផ្សាយកសិកម្ម ចុះប្រមូលទិន្នន័យតួអង្គចម្បងៗក្នុងដំណាក់កាលប្រមូលទិញពីស្រែនៃខ្សែច្រវាក់តម្លៃស្រូវ អង្ករនៅក្នុងរាជធានីភ្នំពេញ ។
- ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម បានជួយសម្របសម្រួលគណៈកម្មការសហគមន៍រៀបចំការប្រជុំបូកសរុបការងារប្រចាំឆ្នាំចំនួន ៧សហគមន៍ និងចូលរួមមហាសន្និបាតប្រចាំឆ្នាំចំនួន ៣សហគមន៍ និងបានចូលរួមសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញលើច្បាប់ ស្តីពីសហគមន៍កសិកម្ម នៅខេត្តកំពង់ចាម ។
- ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម ការិយាល័យផលិតកម្ម និងបសុព្យាបាល ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម ខណ្ឌរដ្ឋបាលព្រៃឈើ ខណ្ឌរដ្ឋបាលជលផល ចុះប្រមូលទិន្នន័យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលធ្វើប្រតិបត្តិការលើវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងរាជធានីភ្នំពេញ។
- ប្រធានការិយាល័យកសិឧស្សាហកម្ម ចូលរួមវគ្គបណ្តុះបណ្តាល " គ្រូបង្គោល(TOT) ស្តីពីខ្សែច្រវាក់តម្លៃដែលគិតគូរពីអាហារូបត្ថម្ភ "។
- នាយរងខណ្ឌរដ្ឋបាលជលផលភ្នំពេញ ចូលរួមវគ្គបណ្តុះបណ្តាលស្តីបទបញ្ញត្តិសហភាពអឺរ៉ុប និងការអនុវត្តល្អក្នុងប្រព័ន្ធគ្រប់គ្រងម្ហូបអាហារ។
- ប្រធានការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម និងអនុប្រធានការិយាល័យផែនការ គណនេយ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការចងក្រងស្ថិតិកសិកម្មលម្អិតតាមតំបន់ ។
- ថ្នាក់ដឹកនាំមន្ទីរ និងប្រធានអង្គភាព/ការិយាល័យជំនាញចូលរួមកិច្ចប្រជុំពិនិត្យផ្ទៀងផ្ទាត់លើរបាយការណ៍វិភាគទិន្នន័យចុងក្រោយនៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤។
- ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម ការិយាល័យផ្សព្វផ្សាយកសិកម្ម ចុះស្រង់ស្ថិតិបរិមាណបន្លែនាំចូលក្នុងរាជធានីភ្នំពេញ ប្រភពនាំចូល និងបរិមាណចែកចាយទៅតាមបណ្តាខេត្ត នៅផ្សារដើមគរ ផ្សារនាគមាស ផ្សារទួលស្វាយព្រៃ ផ្សារច្បារអំពៅ និងផ្សារជម្ពូវ័ន្ត រាជធានីភ្នំពេញ ។

## ខ. ការងារចិញ្ចឹមសត្វ (ឧបសម្ព័ន្ធ ៣)

### ខ.១. ស្ថិតិសត្វ

- គោ ៤ ០២១ ក្បាល (សាច់ ៣ ៦៧៧ក្បាល អូសទាញ ៣៤៤ក្បាល)
- ក្របី ១៤០ ក្បាល(សាច់ ១៣០ក្បាល)
- ជ្រូក ២ ០៤០ ក្បាល(បា ៥ក្បាល មេ ១៦៦ក្បាល កូន ៦៣៥ក្បាល សាច់ ១ ២៣៤ក្បាល)
- សេះ ៧ ក្បាល
- ពពែ ១៦៥ ក្បាល
- ចៀម ២០០ ក្បាល
- ទន្សាយ ១000 ក្បាល
- ឆ្កែ ៨០ ៣៥៥ ក្បាល
- ឆ្មា ១៨ ៩៤៦ ក្បាល
- មាន់ ១៨១ ២៣៨ ក្បាល (មាន់ពង ៦៩០០០ក្បាល មាន់សាច់ ១១២ ៧៣៨ក្បាល)
- ទា ៣៦ ៣៨៥ ក្បាល (ទាកាប ៣៥ ៥៧០ក្បាល និងទាកាប៉ា ៨១៥ក្បាល)
- ក្ងាន ២៣៥ ក្បាល

ការចិញ្ចឹមសត្វសរុបចំនួន **៣២៤ ៧៣២ក្បាល**។

### ខ.២. ស្ថានភាពសត្វឈឺ ការព្យាបាល និងសត្វស្លាប់ដោយជំងឺ

- ការព្យាបាលសត្វសរុប: **១ ៦៦០ក្បាល** «គោ ៧៣ក្បាល ជ្រូក ៧០ក្បាល ឆ្កែ ៨៤៧ក្បាល ឆ្មា ២០០ ក្បាល មាន់ ៤៧០ក្បាល »
- សត្វស្លាប់សរុប: **៣៦៩ក្បាល**«ជ្រូក ៦ក្បាល ឆ្កែ ៩ក្បាល មាន់ ៣៥៤ក្បាល» ។

### ខ.៣.វិធានការការពារជំងឺឆ្លងសត្វ

- មន្ត្រីបសុពេទ្យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ ចូលរួមសហការជាមួយមន្ត្រីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ចុះទប់ស្កាត់ និងអនុវត្តវិធានបសុពេទ្យ នៅទីតាំងអង្គការ Resource Development International នៅភូមិព្រែកធំ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលបន្ទាប់ពីបានបញ្ជូនវត្ថុវិភាគសត្វមាន់ចំនួន២ក្បាល យកទៅវិភាគនៅវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ជាលទ្ធផលវិភាគបង្ហាញថា មាន់ទាំង២ក្បាលខាងលើ មានវត្តមានវីរុសផ្តាសាយបក្សីក្នុងអនុក្រុម H5N1។ នៅទីតាំងខាងលើ មានចិញ្ចឹមសត្វមាន់តូចធំសរុបចំនួន ៤៣៤ក្បាលក្នុងនោះ សត្វមាន់បានស្លាប់ចំនួន ១៥៣ក្បាល (ចាប់ពីថ្ងៃទី១៨/០១/២៥ ដល់ថ្ងៃទី២៧/០១/២៥)និងនៅសល់សត្វមាន់នៅរស់ភាគច្រើនតូចៗចំនួន២៨១ក្បាល ។ តាមរយៈការពិភាក្សាជាមួយមន្ត្រីជំនាញ ខាងអង្គការបានយល់ព្រមសហការសម្លាប់សត្វមាន់ដែលនៅសល់ទាំងអស់។ វិធានការដែលបានអនុវត្តៈ ១-ណែនាំដល់ម្ចាស់សត្វមាន់ពីបច្ចេកទេស និងវិធានការការពារ-ទប់ស្កាត់ជំងឺឆ្លងពីសត្វទៅសត្វ និងឆ្លងពីសត្វទៅមនុស្ស ២-អនុវត្តវិធានជីវសុវត្ថិភាព បាញ់ថ្នាំសម្លាប់មេរោគក្នុង និងជុំវិញទ្រុងសត្វ ៣-បានសម្លាប់ និងដុតកំទេចចោលសត្វមាន់រស់ដែលនៅសល់ទាំងអស់។ វិធានការអនុវត្តបន្ត គឺបន្តចុះតាមដាន ពិនិត្យ និងអនុវត្តវិធានជីវសុវត្ថិភាព បាញ់ថ្នាំសម្លាប់មេរោគជាប្រចាំ ១សប្តាហ៍២ដង ក្នុងរយៈពេល១ខែពេញនៅក្នុង និងជុំវិញតំបន់ផ្ទុះជំងឺ សំដៅទប់ស្កាត់ការឆ្លងរាលដាលជំងឺផ្តាសាយបក្សីពីតំបន់ខាងលើទៅកាន់តំបន់ផ្សេងៗទៀត។

ការចុះពិនិត្យសុខភាពសត្វ និងផលិតផលសត្វ ការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វ និងការធ្វើជីវសុវត្ថិភាព បាញ់ថ្នាំសម្លាប់មេរោគត្រូវបានអនុវត្តជាក់ស្តែងនៅតាមកសិដ្ឋាន សត្តឃាតដ្ឋាន ទីតាំងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ នៅតាមទីផ្សារ ទីសាធារណៈ និងកន្លែងកែច្នៃផលិតផលសត្វ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- ការចាក់វ៉ាក់សាំងសត្វគោ ក្របី ពពែ ជ្រូក ឆ្កែ ឆ្មា មាន់ សរុបចំនួន **៥ ៥៧៧ក្បាល** នៅក្នុងនោះ៖
  - ចាក់វ៉ាក់សាំងសត្វគោ សរុប : **១ ៣៦៣ក្បាល** «សារទឹក ១០៤០ក្បាល អុតក្តាម ២០៣ក្បាល ដុំពកស្បែក ១២០ក្បាល »
  - ចាក់វ៉ាក់សាំងសត្វក្របីសុប: **១៦០ក្បាល** «សារទឹក ៨០ក្បាល អុតក្តាម ៨០ក្បាល »
  - ចាក់វ៉ាក់សាំងសត្វពពែសរុប: **១២៨ក្បាល** «សារទឹក ១២៨ក្បាល »

- ចាក់វ៉ាក់សាំងសត្វជ្រូកសរុប: **១ ១២០ក្បាល** «អុតក្តាម ១២៥ក្បាល ប៉េស្ត ១៩៩ក្បាល អូហ្សេស្គី ៣២៥ក្បាល ជាតិដែក ២៧៥ក្បាល រាគកូនជ្រូក ១៩៦ក្បាល»
- ចាក់វ៉ាក់សាំងសត្វឆ្កែ ឆ្មា សរុប: **១ ២០៦ក្បាល** « ឆ្កែ ៩៧១ក្បាល ឆ្មា ២៣៥ក្បាល»
- ចាក់វ៉ាក់សាំងសត្វមាន់ សរុប :**១ ៦០០ក្បាល**«អាសន្នរោគ ៤៩០ក្បាល ញូវកាស ១១១០ក្បាល »

- ការគ្រៀវសត្វឆ្កែ ឆ្មា សរុបចំនួន **១៦ក្បាល** « ឆ្កែ ៥ក្បាល ឆ្មា ១១ក្បាល»
- ធ្វើជីវសុវត្ថិភាពបាញ់ថ្នាំសម្លាប់មេរោគ សរុប : **៩០៦លើក**
  «ទីតាំងចិញ្ចឹមសត្វ ១៤៦លើក សត្តឃាតដ្ឋាន ៦៨៨លើក ទីផ្សារ ៦៨លើក ផ្លូវជាតិ ៤លើក»។

**ខ.៤. ការត្រួតពិនិត្យអនាម័យសាច់សត្វ នៅទីសត្តឃាតដ្ឋាន**

- គោ **១៧ ០៥៣ក្បាល** ទម្ងន់សាច់ស្អាត ១ ៧៩០ ៥៦៥គ.ក្រ និងសាច់មិនស្អាត ១៨០គ.ក្រ
- ជ្រូក **១៤៣ ១៦៣ក្បាល** ទម្ងន់សាច់ស្អាត ១១ ៥៣០ ៤០គ.ក្រ និងសាច់មិនស្អាត ២១០គ.ក្រ
- មាន់ **៣៨៧ ៧៥៩ក្បាល** គិតជាទម្ងន់សាច់ស្អាត ៤៦៥ ៣១០,៨០គ.ក្រ
- សាច់ និងផលិតផលសត្វទាំងអស់ត្រូវបានអនុវត្តតាមនីតិវិធីនៃការត្រួតពិនិត្យសត្វរស់មុនពេលពិឃាត ត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វក្រោយពេលពិឃាត និងអូសត្រាសម្គាល់ពីមន្ត្រីបសុពេទ្យនៅក្នុងសត្តឃាតដ្ឋាន មុនពេលបញ្ចេញទៅកន្លែងតាំងលក់នៅតាមទីផ្សារ សំដៅធានាបាននូវគុណភាព សុវត្ថិភាពសាច់ និងផលិតផលសត្វ ដើម្បីរួមចំណែករក្សាបាននូវសុខភាពសាធារណៈ និងសុវត្ថិភាពចំណីអាហារនៅក្នុងរាជធានីភ្នំពេញ។ សាច់មិនស្អាតចំនួន **៣៩០គ.ក្រ**(សាច់ហើម ជាំ ដោយការប៉ះទង្គិចក្នុងពេលដឹកជញ្ជូន) ត្រូវបានដុតបំផ្លាញចោលមិនអនុញ្ញាតឱ្យធ្វើចរាចរចូលទីផ្សារឡើយ។

**ខ.៥. ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វនាំចូលរាជធានីភ្នំពេញ**

- បរិមាណជ្រូក ក្នុងស្រុក សរុប: **១៤៣ ១៦៣ក្បាល**
  - ក្រុមហ៊ុន «ស៊ីភី» : ៤២ ៩៤៨ក្បាល
  - ក្រុមហ៊ុនម៉ុងឫទ្ធី : ២៨ ៦៣២ក្បាល
  - ក្រុមហ៊ុនបេតាហ្គ្រោ : ១៤ ៣១៦ក្បាល
  - លក្ខណៈគ្រួសារ : ៧ ១៦០ក្បាល
  - កសិដ្ឋានក្នុងស្រុក : ៥០ ១០៧ក្បាល
- គោ : **១៧ ០៥៣ក្បាល**
- មាន់ : **៣៨៧ ៧៥៩ក្បាល**

**ខ.៦. ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វនាំចេញ ៖ គ្មាន**

**ខ.៧. ទីតាំងលក់ជ្រូកខ្វៃ កន្លែងខ្វៃជ្រូក លក់សាច់ត្រជាក់ ក្នុងរាជធានីភ្នំពេញ**

- ខណ្ឌមានជ័យ ទីតាំងខ្វៃជ្រូក និងលក់ជ្រូកខ្វៃ ០៤កន្លែង
- ខណ្ឌទួលគោក ទីតាំងខ្វៃជ្រូក ០៤កន្លែង លក់សាច់ត្រជាក់ ០២កន្លែង
- ខណ្ឌ៧មករា ទីតាំងខ្វៃជ្រូក ០២កន្លែង លក់ជ្រូកខ្វៃ ១១កន្លែង លក់សាច់ត្រជាក់ ០២កន្លែង
- ខណ្ឌឫស្សីកែវ ទីតាំងខ្វៃជ្រូក ០៣កន្លែង
- ខណ្ឌសែនសុខ លក់សាច់ត្រជាក់ ០៣កន្លែង
- ខណ្ឌច្បារអំពៅ លក់សាច់ត្រជាក់ ០១កន្លែង
- ខណ្ឌបឹងកេងកង ទីតាំងខ្វៃជ្រូក០២កន្លែង ប្រហិត០១កន្លែង ប៉ាតេ០១កន្លែង ។

**ខ.៨.ការងារបង្ក្រាបបទល្មើសចលនាដឹកជញ្ជូនសត្វ ផលិតផលសត្វ**

- ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៥ បានចូលរួមសហការជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ឃាត់រថយន្ត១គ្រឿងម៉ាក MITSUBISHI FUSO ស្លាកលេខ ភ្នំពេញ 3F-1317 ដឹកមាន់រស់ចំនួន៣៦៤០ក្បាលស្មើនឹង៥២០ស្រកា ដោយមិនមានលិខិតអនុញ្ញាត នៅលើដងផ្លូវជាតិលេខ៥ ត្រង់ចំណុចក្បែរវង្វង់

មូល គល់ស្ពានព្រែកព្នៅ ខណ្ឌព្រែកព្នៅ ។ វត្ថុតាងនៃបទល្មើសបានប្រគល់ជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វដើម្បីរក្សាទុក និងអនុវត្តតាមនីតិវិធីនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ។

- ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៥ បានចូលរួមសហការជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ឃាត់រថយន្ត១គ្រឿងម៉ាកសាំយ៉ុង ស្លាកលេខ ភ្នំពេញ 2AE 7704 ដឹកពងមាន់ចំនួន១៥០ដុំ ស្មើនឹង ៤៥០០០គ្រាប់ ដោយមិនមានលិខិតអនុញ្ញាត នៅលើផ្លូវស៊ីជីនពីង ភូមិព្រះធាតុ សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ វត្ថុតាងនៃបទល្មើសបានប្រគល់ជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីរក្សាទុក និងអនុវត្តតាមនីតិវិធីនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ។
- ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៥ បានចូលរួមសហការជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ឃាត់រថយន្ត១គ្រឿងម៉ាកសាំយ៉ុង ស្លាកលេខ ភ្នំពេញ 2L 9476 ដឹកពងមាន់ចំនួន៨០ដុំ ស្មើនឹង ២៤០០០គ្រាប់ ដោយមិនមានលិខិតអនុញ្ញាត នៅលើផ្លូវជាតិលេខ១ មុខវត្តចំប៉ា សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។ វត្ថុតាងនៃបទល្មើសបានប្រគល់ជូន អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីរក្សាទុក និងអនុវត្តតាមនីតិវិធីនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ។

**គ. វិស័យនេសាទ** (ឧបសម្ព័ន្ធ ៤)

**គ.១.អាជីវកម្មនេសាទ**

- ស្ថិតិផលនេសាទៈ

ផលត្រីចាប់បានក្នុងឆមាស សរុបចំនួន **៨៥៩តោន**

  - ឧបករណ៍ឧស្សាហកម្ម (ដាយត្រី) ៤៨៥តោន
  - នេសាទគ្រួសារក្នុងដែននេសាទ ៣៧៤តោន
  - នេសាទគ្រួសារតាមវាលស្រែ ០តោន

ក្នុងឆមាសទី១ឆ្នាំ២០២៥ ការនេសាទមានសកម្មភាពប្រហាក់ប្រហែលឆ្នាំកន្លងទៅ ទាំងការនេសាទឧស្សាហកម្ម(ដាយត្រី) និងការនេសាទជាលក្ខណៈគ្រួសារក្នុងដែននេសាទ ប៉ុន្តែការប្រមូលផលត្រីកើនឡើងជិតពីរដង ប្រៀបធៀបឆមាសទី១ឆ្នាំ២០២៤។ សកម្មភាពអាជីវកម្មនេសាទក្នុងឆមាសទី១ឆ្នាំ២០២៥រួមមាន ឧបករណ៍នេសាទឧស្សាហកម្ម(ដាយត្រី) និងនេសាទជាលក្ខណៈគ្រួសារមាន មង នាម លប ចៃវ៉ា ថ្នង សំណាញ់ សន្ទូច។ល។

**គ.២.ស្ថិតិវារីវប្បកម្ម**

- ត្រីចិញ្ចឹម សរុបចំនួន **៦៦០៦តោន**
  - ចិញ្ចឹមតាមស្រះ ៥៩៣៩តោន
  - ចិញ្ចឹមតាមបែ ៦៦៧តោន
- កង្កែបចិញ្ចឹម សរុបចំនួន **២,៣០តោន**
  - មេពូជចំនួន ៦០០ក្បាល
  - កូនកង្កែបចំនួន ៩ ០០០ក្បាល
- ក្រពើចិញ្ចឹម សរុបចំនួន **២០០ក្បាល**
  - ក្រពើមេ ១៧០ក្បាល
  - ក្រពើបា ៣០ក្បាល

ក្នុងឆមាសទី១ឆ្នាំ២០២៥នេះ ក្រពើចំនួន ៤៨៥ក្បាល ត្រូវបានលក់ចេញ ក្នុងនោះមាន ក្រពើមេ ២០០ក្បាល ក្រពើបា ១៣០ក្បាល និងក្រពើធំទង់ ១៥៥ក្បាល។

- ប្រជាជនយកចិត្តទុកដាក់ពង្រីកមុខរបរចិញ្ចឹមជីវិតតាមរយៈការធ្វើវារីវប្បកម្ម ការប្រមូលផលមានការកើនឡើងប្រមាណ១៥០០តោនប្រៀបធៀបឆមាសទី១ឆ្នាំ២០២៤។ ប្រភេទត្រីដែលដាក់ចិញ្ចឹមរួមមានត្រីប្រាទីឡាព្យ៉ា កាបស កាបសាមញ្ញ ឆ្ពិន ពោ កែ ប្រាខ្មៅ និងកង្កែប។

**គ.៣.ការកែច្នៃផលនេសាទ**

- ការកែច្នៃផលនេសាទ សរុបចំនួន **១ ៤១៦តោន** «ត្រីងៀត ប្រហុក ផ្អក មាំ ត្រីឆ្អើរ ត្រីប្រឡាក់ ប្រហិត .......»
- ផលិតទឹកត្រី សរុបចំនួន **១ ៩៤៦ ៦៤១លីត្រ** ។

- ការចេញលិខិតអនុញ្ញាតឱ្យបង្កើតទីតាំងទិញ លក់សន្និធិ ឬកន្លែងកែច្នៃផល ផលិតផលជលផលក្នុង ត្រីមាស សរុបចំនួន **១០២ច្បាប់។**

**គ.៤.ការនាំចូលផលនេសាទ**

- ការនាំចូលផលនេសាទ សរុបចំនួន **២២ ២៤៩តោន**
  - ផលនេសាទទឹកសាប ចំនួន ១៩ ៥៧៤តោន
  - ផលនេសាទសមុទ្រ ចំនួន ២ ៦៧៥តោន។

**គ.៥.ផលនេសាទនាំចូលពីបណ្តាខេត្ត**

- ផលនេសាទនាំចូលពីបណ្តាខេត្ត សរុបចំនួន **១១ ៨២៩តោន**
  - ផលនេសាទទឹកសាប ចំនួន ៧ ១៤៤តោន
  - ផលនេសាទសមុទ្រ ចំនួន ៤ ៦៨៥តោន។

**គ.៦.ការងារបង្ក្រាបបទល្មើសនេសាទ**

- ក្នុងឆមាសទី១ ឆ្នាំ២០២៥ បានកសាងកំណត់ហេតុបទល្មើសបំផ្លាញចោលសរុបចំនួន **១៥ករណី។** វត្ថុតាងបំផ្លាញចោលរួមមាន៖ លបកន្ទុយកណ្ដុរ ៣០គ្រឿង បង្គោល ១៥ដើម មែកសម្រាស់ ៦០ដើម កានប្រេងចំណុះ៣០លីត្រចំនួន១២ និងលែងកូនត្រីចម្រុះ ២២គីឡូក្រាម។

## **ឃ. ការងារព្រៃឈើ** (ឧបសម្ព័ន្ធ ៥)

**ឃ.១.ការបណ្តុះ ចែកចាយ និងដាំកូនឈើ៖**

- ការបណ្តុះកូនឈើ សរុបចំនួន **៥ ០០០ដើម**
- ការចែកចាយកូនឈើ សរុបចំនួន **១ ៦០៧ដើម**
- ការដាំកូនឈើ សរុបចំនួន **២០១ដើម។**

កូនឈើនៅសល់ក្នុងថ្នាលសរុបចំនួន ២៩ ៥៧៩ដើម ក្នុងនោះ កូនឈើរយៈពេលខ្លី ៨០០ដើម កូនឈើរយៈពេលវែង ២៦ ៨២៩ដើម និងកូនឈើហូបផ្លែ ១ ៩៥០ដើម។

**ឃ.២.រោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ**

- បានចេញលិខិតអនុញ្ញាតបន្តសុពលភាពសរុប៖
  - រោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ ចំនួន **២៣កន្លែង។**
  - រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច **១៧កន្លែង។**
- មានរោងម៉ាស៊ីនអារឈើ និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទមធ្យមចំនួន **៣កន្លែង** ។
- មានរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ(ច្រកចេញចូលតែមួយ) ចំនួន **៣កន្លែង** គឺក្រុមហ៊ុន ធី អេស អឹម ដាប់ប៊ែលយូ ឯ.ក ក្រុមហ៊ុន អៀង ប៊ុនថន និងក្រុមហ៊ុន កែវ ស៊ីម ។

**ឃ.៣.ការដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូល ចេញ**

- ការដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលក្នុងត្រីមាសទី១ សំរាប់ប្រើប្រាស់ក្នុងមូលដ្ឋានមាន ឈើអារចម្រុះប្រភេទសរុប ចំនួន **២ ១៦២ម៣៦៩០** កូនឈើចំនួន **២១៧ដើម** និងអុសចំនួន **១០០ស្ទែរ។**

**ឃ.៤.ការបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ (គ្មាន)**

## **ង. ការងារគណនេយ្យ ហិរញ្ញវត្ថុ** (ឧបសម្ព័ន្ធ ៦)

**ង.១.ចំណូល :**

- ចំណូលសរុបចំនួន **៤៣១ ៧៧៦ ០០០រៀល** ក្នុងនោះ ៖

(កើន ២១៧ ៩៧៥ ៥០០រៀល ធៀបឆមាសទី១ ឆ្នាំ២០២៤)

  - ចំនួន ៣០២ ១៧៦ ០០០រៀល ជាកម្រៃសេវាពីផ្នែកផលិតកម្ម និងបសុព្យាបាល (បង់ចូលថវិកាជាតិ តាមរយៈអង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ)។

- ចំនួន ៩៧ ៦០០ ០០០រៀល ជាកម្រៃសេវាពីផ្នែកជលផល(ឈ្នួលដាយត្រី) (បង់ចូលថវិកាជាតិ តាមរយៈរដ្ឋបាលរាជធានីភ្នំពេញ)។
- ចំនួន ៣២ ០០០ ០០០រៀល ជាកម្រៃមកពីសេវាសាធារណៈចេញលិខិតអនុញ្ញាត របស់ខណ្ឌរដ្ឋបាលព្រៃឈើ (បង់ចូលថវិកាជាតិតាមរយៈរដ្ឋបាលព្រៃឈើ)។

**ង.២.ចំណាយ :**

- ចំណាយ សរុបចំនួន **១ ៧៨២ ៩៦១ ១៥០រៀល** ក្នុងនោះ៖

(ថយ ៤៤ ៤២០ ២៤០រៀល ធៀបឆមាសទី១ ឆ្នាំ២០២៤)

- ចំនួន ១ ៦៨៩ ៨៦៧ ៤២០រៀល ជាបៀវត្សមន្ត្រីរាជការ (ជំពូក៦៤)
- ចំនួន ៣៧ ៩២០ ០០០រៀល ជាប្រាក់កម្រៃបុគ្គលិកជាប់កិច្ចសន្យា (ជំពូក៦៤)
- ចំនួន ៨ ១០០ ០០០រៀល ជាប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំប្រពៃណីជាតិ (ជំពូក៦៤)
- ចំនួន ២០ ៣២៤ ៦៤០រៀល ជាប្រាក់ឧបត្ថម្ភមន្ត្រីចូលនិវត្តន៍ (ជំពូក៦៤)
- ចំនួន ១៥ ៩២៤ ០៩០រៀល ជាការទិញ (ជំពូក៦០)
- ចំនួន ១០ ៣២៥ ០០០រៀល ជាការទិញ (ជំពូក៦១)

## ច. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យ អង្គភាពក្រោមឱវាទ (ឧបសម្ព័ន្ធ ៧)

| ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យ និង អង្គភាពក្រោមឱវាទ | កិច្ចប្រជុំ សិក្ខាសាលា សន្និបាត.... | ពិធីផ្សេងៗ | សរុប |
|---|---|---|---|
| ថ្នាក់ដឹកនាំមន្ទីរ | ៨៨ | ១០ | ៩៨ |
| ខណ្ឌរដ្ឋបាលព្រៃឈើ | ៨ | ៥ | ១៣ |
| ខណ្ឌរដ្ឋបាលជលផល | ១០ | ២ | ១២ |
| ការិ.រដ្ឋបាល បុគ្គលិក | ១៣ | ១ | ១៤ |
| ការិ.ផែនការ គណនេយ្យ | ៣០ | ១ | ៣១ |
| ការិ.ផលិតកម្ម និងបសុព្យាបាល | ៩ | - | ៩ |
| ការិ.ក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម | ៧ | ១ | ៨ |
| ការិ.គ្រឿងយន្តកសិកម្ម | ១ | - | ១ |
| ការិ.ផ្សព្វផ្សាយកសិកម្ម | ១ | ១ | ២ |
| ការិ.អភិវឌ្ឍន៍សហគមន៍កសិកម្ម | ៣ | ១ | ៤ |
| ការិ.កសិឧស្សាហកម្ម | ៣ | ១ | ៤ |
| ការិ.នីតិកម្មកសិកម្ម | ២ | ១ | ៣ |
| ការិ.កៅស៊ូ | ១ | ១ | ២ |

## ឆ. បញ្ហាប្រឈម និងដំណោះស្រាយ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| **១. ការងារបង្កបង្កើនផល** | | |
| | ការយល់ដឹងរបស់ប្រជាកសិករនៅមានកម្រិត ក្នុងផលិតកម្មកសិកម្ម និងការបង្កើនទិន្នផលស្រូវ និងដំណាំ។ | ចាត់មន្ត្រីជំនាញចុះផ្សព្វផ្សាយណែនាំបច្ចេកទេសសាមញ្ញៗ ដែលកសិករអាចយកទៅអនុវត្តបាន ដើម្បីជួយកសិករពង្រឹងសមត្ថភាព បច្ចេកទេស សំដៅបង្កើនទិន្នផលស្រូវ និងដំណាំឲ្យទទួលបានផលខ្ពស់ មានដូចជា៖<br>១.ករណីដីស្រែប្រភេទដីអាស៊ីត(PHតិច)ត្រូវបាចកំបោរស ឬផេះ ដើម្បីបង្កើន(PH) ឲ្យបាន ៦,៥-៧,៥ |

| | | |
|---|---|---|
| | | ២.ត្រូវភ្ជួររលុបចំបើង និងគល់ជញ្ជ្រាំងចូលក្នុងដី បន្ទាប់ពីប្រមូលផលស្រូវរួច ដើម្បីបង្កើនសារធាតុចិញ្ចឹម NPK<br>៣.ការរៀបចំដី ត្រូវពង្រាបដីឲ្យបានរាបស្មើ ងាយស្រួល ក្នុងការគ្រប់គ្រងទឹក និងសារធាតុចិញ្ចឹមបានស្មើគ្នា<br>៤.មុនសាប ស្ទូង និងព្រោះ ត្រូវប្រើប្រាស់ជីសរីរាង្គទ្រាប់បាត<br>៥.ប្រើប្រាស់គ្រាប់ពូជស្រូវសុទ្ធល្អ<br>៦.ចុះស្រែជាប្រចាំ ដើម្បីគ្រប់គ្រងទឹក សត្វល្អិត ជំងឺ និងគ្រប់គ្រងសារធាតុចិញ្ចឹម<br>៧.ការទុកដាក់គ្រាប់ពូជស្រូវ ត្រូវប្រួតកាត់ក្នុងសំណើម២១%-២៥% ហាលឲ្យស្ងួតល្អរហូតត្រឹមសំណើម១៣%-១៤%។ |
| **២. ការងារចិញ្ចឹមសត្វ** | | |
| | ដោយសារកំណើនប្រជាពលរដ្ឋមករស់នៅប្រកបរបរ ទទួលទាននៅរាជធានីភ្នំពេញកាន់តែច្រើនធ្វើឲ្យសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតឲ្យបង្កើតពីពេលមុនដែលស្ថិតនៅឆ្ងាយពីទីប្រជុំជន និងទីសាធារណៈនានាបានប្រែក្លាយជាមានប្រជាពលរដ្ឋមករស់នៅជុំវិញយ៉ាងកុះករ ធ្វើឲ្យមានការរំខាន និងប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្បែរខាង ។ | -ចុះពិនិត្យការអនុវត្តវិធានបសុពេទ្យ បទដ្ឋានអនាម័យ និងបច្ចេកទេសនៅតាមសត្តឃាតដ្ឋានដែលមានលិខិតអនុញ្ញាតរួចពីមុនសំដៅជំរុញការពង្រឹងការអនុវត្តច្បាប់ ដើម្បីកាត់បន្ថយការប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្បែរខាង<br>-សត្តឃាតដ្ឋានដែលនឹងត្រូវស្នើសុំបង្កើតថ្មីអាចពិនិត្យ និងសម្រេចផ្តល់ជូនបានលុះត្រាមានតែទីតាំងនៅជាយរាជធានីឆ្ងាយពីទីប្រជុំជន និងជាតម្រូវការចាំបាច់តែប៉ុណ្ណោះ។ |

## ៦. ផែនការប្រចាំខែកក្កដា ឆ្នាំ២០២៥

| ល.រ | សកម្មភាពជាអាទិភាព | កក្កដា |
|---|---|---|
| | **ក.ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម** | |
| ១ | ចុះផ្សព្វផ្សាយ និងជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំរដូវប្រាំង ឆ្នាំ២០២៤-២០២៥។ | ✓ |
| ២ | ចុះផ្សព្វផ្សាយណែនាំបច្ចេកទេសសមស្របដល់កសិករ ដើម្បីបង្កើនទិន្នផលស្រូវ និងដំណាំផ្សេងៗ។ | ✓ |
| ៣ | សហការជាមួយការិយាល័យជំនាញ និងមន្ទីរធនធានទឹក និងឧតុនិយមរាជធានីភ្នំពេញ ដើម្បីរៀបចំផែនការត្រៀមសម្រាប់អន្តរាគមន៍ក្នុងករណីមានគ្រោះធម្មជាតិកើតឡើង។ | ✓ |
| | **ខ.ការិយាល័យផលិតកម្ម និងបសុព្យាបាល** | |
| ៤ | បង្កើនការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលមានដើមកំណើតពីសត្វ។ | ✓ |
| ៥ | ជំរុញការងារចិញ្ចឹមសត្វ ជាលក្ខណៈគ្រួសារ និងពាក់កណ្តាលឧស្សាហកម្ម។ | ✓ |
| ៦ | បង្កើនការត្រួតពិនិត្យការស្តុក ការដឹកជញ្ជូនចលនាសត្វរស់ និងផលិតផលមានដើមកំណើតពីសត្វ ចេញ ចូលរាជធានីភ្នំពេញ និងមានវិធានការទប់ស្កាត់ជំងឺឆ្លងសត្វ។ | ✓ |
| ៧ | កែលម្អរចនាសម្ព័ន្ធសត្តឃាតដ្ឋានឲ្យមានអនាម័យសមស្របតាមលក្ខណៈបច្ចេកទេស។ | ✓ |
| ៨ | ជំរុញម្ចាស់សត្តឃាតដ្ឋានដែលមិនទាន់បានបំពេញបែបបទលិខិតស្នាមស្នើសុំបង្កើតសត្តឃាតដ្ឋានតាមខ្លឹមសារនៃអនុក្រឹត្យលេខ ១០៨ អនក្រ.បក ឲ្យបានទាន់ពេលវេលា។ | ✓ |
| ៩ | ត្រៀមថ្នាំសម្រាប់ព្យាបាលសត្វក្នុងករណីមានគ្រោះធម្មជាតិ ឬជំងឺឆ្លងសត្វកើតឡើង។ | ✓ |
| ១០ | ត្រួតពិនិត្យទីតាំងសាច់ត្រជាក់នៅតាមបណ្តាខណ្ឌ។ | ✓ |
| | **គ.ខណ្ឌរដ្ឋបាលជលផល** | |
| ១១ | ចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ។ | ✓ |
| ១២ | តាមដាន និងត្រួតពិនិត្យការធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទ។ | ✓ |
| ១៣ | ជំរុញការធ្វើវារីវប្បកម្មឲ្យបានទូលំទូលាយ ពិសេសតំបន់ជាយរាជធានីភ្នំពេញ។ | ✓ |
| | **ឃ.ខណ្ឌរដ្ឋបាលព្រៃឈើ** | |
| ១៤ | ចុះពិនិត្យ ថែទាំ ដាំជួសដើមឈើដែលបានដាំរួចនៅតាមដងផ្លូវក្នុងរាជធានី។ | ✓ |
| ១៥ | ថែទាំ និងចែកចាយកូនឈើសម្រាប់ដាំក្នុងរាជធានីភ្នំពេញ។ | ✓ |
| ១៦ | ចុះផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានផ្សេងៗ។ | ✓ |
| ១៧ | ចុះត្រួតពិនិត្យ និងកាត់ស្តុកតាមរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ។ | ✓ |
| ១៨ | ចុះត្រួតពិនិត្យការដឹកជញ្ជូនផល អនុផលព្រៃឈើ ចូល ចេញ និងឆ្លងកាត់។ | ✓ |
| ១៩ | ចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ។ | ✓ |

| | | |
|---|---|---|
| | **ង.ការិយាល័យផ្សេងៗ** | |
| ២០ | ជំរុញការអនុវត្ត និងណែនាំបច្ចេកទេសបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ | ✓ |
| ២១ | បន្តចុះពិនិត្យលើការប្រើប្រាស់ឧបករណ៍កសិកម្មក្នុងការបង្កបង្កើនផលស្រូវ។ | ✓ |
| ២២ | ចុះធ្វើបច្ចុប្បន្នភាពទីតាំងលក់គ្រឿងយន្តកសិកម្មក្នុងរាជធានីភ្នំពេញ។ | ✓ |
| ២៣ | បន្តចូលរួមសម្របសម្រួលពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍កសិកម្ម។ | ✓ |
| ២៤ | ចុះផ្សព្វផ្សាយច្បាប់សហគមន៍កសិកម្ម និងពង្រឹងការងារគ្រប់គ្រងសហគមន៍កសិកម្ម។ | ✓ |
| ២៥ | ចុះធ្វើបច្ចុប្បន្នភាពទីតាំងកែច្នៃផលិតផលកសិកម្ម។ | ✓ |
| ២៦ | ចុះផ្សព្វផ្សាយបច្ចេកទេសកែច្នៃផលិតផលកសិកម្មក្រោយពេលប្រមូលផលដល់កសិករ។ | ✓ |
| ២៧ | ចុះសួរតម្លៃផលិតផលកសិ-ឧស្សាហកម្មនៅតាមផ្សារធំៗក្នុងរាជធានី។ | ✓ |
| ២៨ | ចុះធ្វើបច្ចុប្បន្នភាព និងត្រួតពិនិត្យទីតាំងលក់ជីកសិកម្ម និងថ្នាំកសិកម្មតាមខណ្ឌក្នុងរាជធានី។ | ✓ |
| ២៩ | បន្តទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានកៅស៊ូ និងស្ថាប័នពាក់ព័ន្ធក្នុងការបំពេញការងារ។ | ✓ |
| ៣០ | ប្រមូលទិន្នន័យកៅស៊ូ និងតម្លៃកៅស៊ូ។ | ✓ |

ថ្ងៃ ពុធ ១៤រោច ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២៥

**ជ.ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ**

**អនុប្រធានមន្ទីរ**